INTERNET ARCHIVE WaybackMachine https://gdlf-kh.com/2020/06/12/ក្រុមហ៊ុន-ខានូពី-អ៊ែន-ឌី/ Go
1 capture
12 Aug 2021
JUL AUG SEP
2020 12 2021 2022
About this capture

ព័ត៌មានក្នុងប្រទេស

ក្រុមហ៊ុន ខានូពី អ៊ែន ឌីវេឡុបម៉ឺន ឯ.ក (CANOPY SANDS DEVELOPMENT CO., LTD) បានធ្វើបទបង្ហាញគម្រោងអភិវឌ្ឍន៍ប្លង់មេ នៃទីក្រុងរាម លើផ្ទៃដី ៨៣៤ហិកតា

Kao sophy ព្រះសីហនុ

ខេត្តព្រះសីហនុ៖ នៅរសៀលថ្ងៃព្រហស្បតិ៍ ៦រោច ខែជេស្ឋ ឆ្នាំជូត ទោស័ក ព.ស ២៥៦៤ ត្រូវនឹងថ្ងៃទី១១ ខែមិថុនា ឆ្នាំ២០២០ ក្រុមហ៊ុន ខានូពី អ៊ែន ឌីវេឡុបម៉ឺន ឯ.ក (CANOPY SANDS DEVELOPMENT CO., LTD) បានធ្វើបទបង្ហាញគម្រោងអភិវឌ្ឍន៍ប្លង់មេ នៃទីក្រុងរាម លើផ្ទៃដី ៨៣៤ហិកតា ស្ថិតនៅឃុំរាម ស្រុកព្រៃនប់ ខេត្តព្រះសីហនុ ក្រោមអធិបតីភាព ឯកឧត្តម គួច ចំរើន អភិបាល នៃគណៈអភិបាលខេត្តព្រះសីហនុ លោកអភិបាលរងខេត្ត លោកនាយករដ្ឋបាលសាលាខេត្ត និងលោក លោកស្រី ជាប្រធានមន្ទីរ អង្គភាពជំនាញក្នុងខេត្តផងដែរ។

តំណាងក្រុមហ៊ុន ខានូពី អ៊ែន ឌីវេឡុបម៉ឺន ឯ.ក (CANOPY SANDS DEVELOPMENT CO., LTD) បានធ្វើបទបង្ហាញ ស្តីពីគម្រោងអភិវឌ្ឍន៍ប្លង់មេ នៃទីក្រុងរាមលើផ្ទៃដី ៨៣៤ហិកតា។គម្រោងនេះត្រូវបានប៉ាន់ប្រមាណថា នឹងមានទុនវិនិយោគរហូតដល់ ១៦ ពាន់លានដុល្លារ ដែលនឹងក្លាយ ជាតំបន់ដែលមានសក្តានុពលធំបំផុតនៅតំបន់ឆ្នេរសមុទ្រកម្ពុជា រួមចំណែកដល់ការអភិវឌ្ឍសេដ្ឋកិច្ច ផ្តល់ ការងារធ្វើជាច្រើនសម្រាប់យុវជន និងប្រែក្លាយទៅជាតំបន់អភិវឌ្ឍន៍ទេសចរណ៍បែបតំរូតាមទស្សនទាន “ស្អាត” ។ គម្រោងអភិវឌ្ឍក្រុងរាមចែកជាបីជំហាន ជំហានទី១ បញ្ចប់នៅឆ្នាំ២០២៥ ជំហានទី២ បញ្ចប់ឆ្នាំ២០៣៥ និងជំហានទី៣ បញ្ចប់នៅឆ្នាំ២០៤៥ ក្នុងនោះ រួមមានការរៀបចំហេដ្ឋារចនាសម្ព័ន្ធ និង សំណង់ផ្សេងៗដូចជាសណ្ឋាគារ ភោជនីយដ្ឋាន អាហារដ្ឋាន រមណីយដ្ឋាន អគារស្នាក់នៅសាលប្រជុំ សាលសន្និសិទ អគារស្នាក់នៅរួម មជ្ឈមណ្ឌលពាណិជ្ជកម្ម ហិរញ្ញវត្ថុ មជ្ឈមណ្ឌលកីឡា ក្នុងនោះក៏មានកីឡាវាយកូនគោលផងដែរ។ គម្រោងនេះនឹងត្រូវរៀបចំឆ្នេរខ្សាច់ ស្អាតពីរកន្លែងដើម្បីប្រើប្រាស់ជាសាធារណៈ សម្រាប់ការអភិវឌ្ឍនៅតំបន់នោះផង ក៏ដូចជាសាធារណជន ចេញចូលប្រើប្រាស់ តំបន់នោះដែលបច្ចុប្បន្នមិនទាន់មានឆ្នេរខ្សាច់សស្អាតនៅឡើយ។

ឯកឧត្តម គួច ចំរើន អភិបាលខេត្តព្រះសីហនុ បានថ្លែងអំណរគុណដល់ក្រុមហ៊ុន ខានូពី អ៊ែន ឌីវេឡុបម៉ឺន ឯ.ក (CANOPY SANDS DEVELOPMENT CO., LTD) ដែលបានធ្វើបទបង្ហាញគម្រោងប្លង់សាងសង់ក្រុងរាម និងសុំឱ្យសិក្សាបានលឿនឆាប់ចប់កាន់តែល្អ ដើម្បីលើកជាប៉ាណូទីតាំងបង្ហាញសាធារណជន និងស្នើឱ្យក្រុមហ៊ុនរៀបចំសិក្ខាសាលាដាក់បង្ហាញប្លង់មេរបស់ខ្លួនដល់គណៈវិស្វករ ដើម្បីប្រមូលធាតុចូល ក៏ដូចជាមតិយោបល់កែលម្អបន្ថែម ធ្វើគម្រោងប្លង់មេនេះកាន់តែល្អឥតខ្ចោះ ក្នុងការអភិវឌ្ឍទីក្រុងទំនើបស៊ីវិល័យ សម្រាប់ប្រជាពលរដ្ឋ និងទាក់ទាញភ្ញៀវទេសចរកាន់តែច្រើនឡើងមកលេងកម្សាន្តនៅខេត្តព្រះសីហនុ៕

Share on Facebook | Tweet | Follow us

← កិច្ចប្រជុំបូកសរុបលទ្ធផលការងារប្រយុទ្ធប្រឆាំងអំពើជួញដូរ មនុស្សប្រចាំឆមាសទី១ និងទិសដៅបន្តឆមាសទី២ ឆ្នាំ២០២០

យុវជនម្នាក់ធ្លាក់ពីលើម៉ូតូត្រូវរថយន្តកិនបែកក្បាលស្លាប់ភ្លាមៗនៅនឹងកន្លែងកើតហេតុ →

You May Also Like

សម្តេចក្រឡាហោម ស ខេង ឧបនាយករដ្ឋមន្ត្រី រដ្ឋមន្ត្រីក្រសួងមហាផ្ទៃ អនុញ្ញាតជូនឯកឧត្តម W. Patrick Murphy ឯកអគ្គរដ្ឋទូតសហរដ្ឋអាមេរិកប្រចាំកម្ពុជា ចូលជួបពិភាក្សាការងារ

លោកឧត្តមសេនីយ៍ទោ ខូវ លី បានជម្រុញឱ្យគ្រប់ផ្នែកត្រូវការពារសន្តិសុខសណ្តាប់ធ្នាប់ សុវត្ថិភាព ជូនបងប្អូនប្រជាពលរដ្ឋ ក្នុងឱកាសបុណ្យចូលឆ្នាំចិន-វៀតណាម នាពេលខាងមុខ

ថ្នាក់ដឹកនាំស្រុកកំពង់ត្រឡាច បានចុះសួរសុខទុក្ខ លោក នួន សឺន មេឃុំតាជេស ដែលកំពុងសម្រាកព្យាបាលជំងឺនៅគេហដ្ឋាន

វីដេអូរសន្តិសុខសង្គម

សេចក្តីជូនដំណឹង

ព័ត៌មានក្នុងប្រទេស សេចក្តីជូនដំណឹង

ខេត្តកំពង់ឆ្នាំង បន្តរកឃើញអ្នកវិជ្ជមានកូវីដ-១៩ ចំនួន ៣១នាក់ អ្នកមរណភាពចំនួន ០១នាក់ អ្នកជាសះស្បើយចំនួន ១០នាក់ នៅថ្ងៃទី១០ ខែសីហា ឆ្នាំ២០២១

Sam Sophearum

ខេត្តកំពង់ឆ្នាំង៖ សេចក្តីប្រកាសព័ត៌មាន របស់រដ្ឋបាលខេត្តកំពង់ឆ្នាំង ស្តីពី ការបន្តរកឃើញអ្នកវិជ្ជមានកូវីដ-១៩ តាមរយៈការធ្វើតេស្តរហ័ស (Rapid Test) ចំនួន ៣១នាក់, អ្នកមរណភាពចំនួន ០១នាក់(ស្រី) អ្នកជាសះស្បើយចំនួន ១០នាក់ នៅថ្ងៃទី១០ ខែសីហា ឆ្នាំ២០២១។ អ្នកវិជ្ជមានកូវីដ-១៩ ខាងលើ បានដាក់ឱ្យសម្រាកព្យាបាលនៅមន្ទីរពេទ្យខេត្តកំពង់ឆ្នាំង,

ព័ត៌មានសុខភាព និងសម្រស់

វិធីសង្គ្រោះបន្ទាន់នៅពេលលង់ទឹក!!!

សុខភាព និងសម្រស់

វិធីសង្គ្រោះបន្ទាន់នៅពេលលង់ទឹក!!!

daraly

ការលង់ ឬការជិតស្លាប់ដោយសារលង់ទឹក ច្រើនតែជាបញ្ហាដែលគេតែងតែហៅឲ្យអ្នកធ្វើការផ្នែកវេជ្ជសាស្ត្រសង្គ្រោះបន្ទាន់១មកជួយសង្គ្រោះ មុននឹងបញ្ជូនជនរងគ្រោះទៅកាន់មន្ទីរពេទ្យ។ នៅក្នុងការលង់ទឹក ទឹកកម្រចូលសួតក្នុងបរិមាណច្រើន ពីព្រោះនៅពេលប៉ះនឹងវត្ថុរាវ ការកន្ត្រាក់បំពង់កកើតឡើង ហើយការកន្ត្រាក់ទាំងនេះនឹងបិទដង្ហើមពីមាត់ និងច្រមុះ។ ១) អាទិភាពដំបូងបំផុតនៅក្នុងការគ្រប់គ្រងជនរងគ្រោះលង់ទឹក គឺរក្សាសុវត្ថិភាពបុគ្គលិកជួយសង្គ្រោះ។ អ្នកជួយសង្គ្រោះគួរពិចារណាពីលទ្ធភាពនៃការកើតមានរបួសនៅនឹងឆ្អឹងខ្នងរបស់ជនរងគ្រោះ ប្រសិនបើទាក់ទងនឹងគ្រោះថ្នាក់នៃការលោត ឬជ្រមុជទឹក ឬមិនដឹងមូលហេតុ។ គួរតែសែងយកអ្នករងគ្រោះចេញពីទឹកដោយប្រើក្តារបន្ទះរឹងជាជំនួយ។ ២) ដើម្បីជៀសវាងមានបញ្ហាធ្ងន់ធ្ងរពីការខ្វះអុកស៊ីសែន

ភ្នែកជាផ្នែកមួយដែលមានសារៈសំខាន់បំផុតចំពោះមនុស្សគ្រប់គ្នា តើយើងគួរធ្វើដូចម្តេចខ្លះដើម្បីការពារភ្នែកកុំអោយមានបញ្ហា
03/09/2020

ព័ត៌មានសិល្បៈ

ធ្លាប់ដឹងទេថាមនុស្សស្រីកាចឆ្នាស់ឆ្អើម មានកត្តាល្អជាច្រើន

សិល្បៈ

ធ្លាប់ដឹងទេថាមនុស្សស្រីកាចឆ្នាស់ឆ្អើម មានកត្តាល្អជាច្រើន

daraly

មនុស្សយើងមើលពីសម្បកក្រៅមិនអាចទាយដល់ចិត្តបានទេ។ ម៉្យាងទៀតដូចពាក្យទូន្មានដែលថាកុំវាយតម្លៃមនុស្សតាមសម្បកខាងក្រៅពិតជាមិនខុសនោះទេ។ វប្បធម៌ប្រទេសយើង រមែងឲ្យតម្លៃទៅមនុស្សស្រីដែលមានឥរិយាបថស្រគត់ស្រគំ ទន់ភ្លន់ និងនិយាយពីរោះពិសារ តែផ្ទុយទៅវិញស្រីៗមានចរិតឆ្នាស់ឆ្អើម គឺមិនជាប់ចំណាត់ថ្នាក់ឡើយ។ ដូច្នេះហើយ ខាងក្រោមនេះជាចំនុចដែលគួរអោយកត់សំគាល់ និងជាការពិតមួយអំពីរបស់មនុស្សស្រីចរិតឆ្នាស់ឆ្អើមនេះ៖ ១. មនុស្សស្រីកាចឆ្នាស់ឆ្អើមរមែងជាមនុស្សជោគជ័យ៖ អ្នកមានចរិតឆ្នាសជាទូទៅមានលក្ខណៈច្បាស់លាស់ ទើបនាងមានទំនុកចិត្តខ្ពស់ថាបានសម្រេចក្នុងកិច្ចការផ្សេងៗ ដូច្នេះហើយទើបនាងមិនចុះញ៉មនឹងគំនិតអ្នកណាឡើយ។ នាងជាទូទៅត្រូវបានគេស្អប់ព្រោះតែភាពជាម្ចាស់ការនិយាយបញ្ចេញយោបល់របស់ខ្លួនទៅលើរឿងអ្វីមួយដែលខុសឆ្គងរបស់អ្នកផ្សេងនោះ។ ប៉ុន្តែការងារភាគច្រើនដែលដឹកនាំដោយស្ត្រីឆ្នាស់នេះតែងបានជោគជ័យ។ ២.

ក្រសួងវប្បធម៌ នឹងហៅអ្នកចម្រៀងទាំងអស់ទៅអប់រំករណីកាឡៃចម្រៀងមរតកដើម

ព័ត៌មានទេសចរណ៍

ទេសចរណ៍

នាឱកាសបុណ្យភ្ជុំបិណ្ឌរយៈពេល៣ថ្ងៃនៅបន្ទាយមានជ័យមានភ្ញៀវជាង៤មឺននាក់ទៅកំសាន្តនៅរមណីយដ្ឋាននានាក្នុងខេត្ត

20/09/2020 Noun Vanny

ខេត្តបន្ទាយមានជ័យ ៖ មានភ្ញៀវទេសចរណ៍មកទស្សនាកម្សាន្តនៅតាមរមណីយដ្ឋាននានា នាឱកាសបុណ្យភ្ជុំបិណ្ឌប្រពៃណីជាតិខ្មែរ រយៈពេល៣ថ្ងៃ សរុបមានចំនួន ៤២.៥០៨ នាក់ ភ្ញៀវទេសចរណ៍ជាតិ ចំនួន ៤២.៥០៨ នាក់ ឯភ្ញៀវទេសចរណ៍អន្តរជាតិគ្មាន ។ លោក ឈឿង សេរីវុធ ប្រធានមន្ទីរទេសចរណ៍ខេត្តបន្ទាយមានជ័យបានអោយដឹងថ្ងៃទី១៩ ខែកញ្ញាថា ៖

បងប្អូនប្រជាពលរដ្ឋមកលេងកម្សាន្តនៅទួលពាន់តាឡីច្រើនក្នុងឱកាសនៃការឈប់សម្រាកនេះ

© ២០១៩. រក្សាសិទ្ធិគ្រប់យ៉ាងដោយ ការិយាល័យផ្សព្វផ្សាយតាមបណ្តាញសង្គម នៃនាយកដ្ឋានផ្សព្វផ្សាយអប់រំ អគ្គនាយកដ្ឋានភស្តុភារ និងហិរញ្ញវត្ថុ ក្រសួងមហាផ្ទៃ